01658504

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D266/25

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥)

**<u>អង្គបុរេជំនុំជម្រះ</u>**

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២០**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 11 / 2020
ម៉ោង (Time/Heure) : 13 : 43
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ:**

## សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត

---

**<u>សហព្រះរាជអាជ្ញា:</u>**
ជា លាង
Brenda J. HOLLIS

**<u>សហមេធាវីការពារក្តី យឹម ទិត្យ:</u>**
អាង ឧត្តម
Michael G. KARNAVAS

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រ៊ីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN- NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត" ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ("សំណើ")[1]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ "ដីកាដំណោះស្រាយ" របស់ខ្លួន ដោយបញ្ជូន មាស មុត ទៅជំនុំជម្រះ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[2] ចំណែកសហចៅក្រមស៊ើបអង្កេតជាតិបានចេញ "ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត" របស់ខ្លួន ("ដីកាសម្រេចលើកលែងចោទប្រកាន់")[3] (រួមគ្នាហៅថា "ដីកាដំណោះស្រាយ")។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានដាក់ជាភាសាអង់គ្លេសតែមួយភាសា ហើយដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានដាក់ជាភាសាខ្មែរតែមួយភាសា ចំណែកឯសំណៅបកប្រែដីកាដំណោះស្រាយទាំងពីរបានដាក់តាមក្រោយ។

២. នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4] ជាភាសាខ្មែរ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ សហមេធាវីការពារក្តី មាស មុត ("សហមេធាវី") បានដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅ

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៣") (អបជ៣៥), សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០, ឯកសារ D266/22 ("សំណើ (D266/22)")។

[2] សំណុំរឿង ០០៣, ដីកាដំណោះស្រាយ, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨, ឯកសារ D267។

[3] សំណុំរឿង ០០៣, ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨, ឯកសារ D266។

[4] សំណុំរឿង ០០៣, បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩, ឯកសារ D267/3 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3)")។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

ជំនុំជម្រះ[5] ហើយសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់[6] ជាភាសាអង់គ្លេស។

៣. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ("សេចក្តីពិចារណា") នៅក្នុងសំណុំរឿង ០០៤/២[7]។

៤. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានផ្សព្វផ្សាយដល់ភាគីដោយចម្លងជូនអង្គបុរេជំនុំជម្រះ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង និងប្រធានការិយាល័យរដ្ឋបាលស្តីទី អនុប្រធានការិយាល័យរដ្ឋបាល នូវអនុស្សរណៈអន្តរការិយាល័យមួយរបស់ចៅក្រមអន្តរជាតិ អមជាមួយឧបសម្ព័ន្ធ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានានៅក្នុងអង្គជំនុំជម្រះ ចាប់តាំងពីពេលចេញសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ដោយបញ្ជាក់ថា អង្គបុរេជំនុំជម្រះបានចាត់វិធានរដ្ឋបាលចាំបាច់ទាំងអស់ដើម្បីបញ្ជូនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង[8]។

---

[5] សំណុំរឿង ០០៣, បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩, ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4)")។

[6] សំណុំរឿង ០០៣, បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2)")។

[7] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") (អបជ៦០), សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ("សេចក្តីពិចារណាលើសំណុំរឿង ០០៤/២ (D359/24 និង D360/33)")។

[8] សំណុំរឿង ០០៤/២, អនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ Kang Jin BAIK និងចៅក្រម Olivier BEAUVALLET ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/36 និង D360/45។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

៥. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធានអង្គបុរេជំនុំជម្រះបានចេញអនុស្សរណៈអន្តរការិយាល័យមួយដោយអះអាងថា មានតែផ្នែកនៃសេចក្តីពិចារណាដែលត្រូវបានសម្រេចជាឯកច្ឆ័ន្ទប៉ុណ្ណោះទើបមានអានុភាពអនុវត្ត[9]។

៦. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ សហមេធាវីបានដាក់ "សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២" ("សំណើសុំការបញ្ជាក់បំភ្លឺ") ដោយស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (១) សម្រេចទទួលយកសំណើ និង (២) ផ្តល់ការបញ្ជាក់បំភ្លឺតាមសំណើ ពាក់ព័ន្ធនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ[10]។

៧. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយជាសាធារណៈ ពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២ ដោយថ្លែងថា អង្គជំនុំជម្រះមិនបានចូលពិនិត្យមើលសំណុំរឿង ០០៤/២ ដោយពុំមានការជូនដំណឹង ឬការបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងទេ ("សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូង")[11]។ ទោះបីចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ទទ្ធីករណ៍អាចលើកឡើងបានក្នុងកាលៈទេសៈពិសេសទាំងនេះថា អង្គជំនុំជម្រះសាលាដំបូងមាន "សិទ្ធិអំណាចពិសេស" ក្នុងការដោះស្រាយបញ្ហាមួយចំនួនក្តី តែចៅក្រមជាតិបានថ្លែងថា បញ្ហានានាត្រូវបានបិទបញ្ចប់នៅចំពោះមុខអង្គបុរេ

---

[9] សំណុំរឿង ០០៤/២, អនុស្សរណៈអន្តរការិយាល័យដែលចេញដោយចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/37 និង D360/46។

[10] សំណុំរឿង ០០៣, សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D266/19 និង D267/24 ("សំណើសុំការបញ្ជាក់បំភ្លឺ (D266/19 និង D267/24)")។

[11] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសំណុំរឿង ០០៤/២ ដែលពាក់ព័ន្ធនឹង អោ អាន" ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ("សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង")។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ជំនុំជម្រះ ហើយថា "នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន នៅពេលនេះ ឬនៅពេលអនាគតឡើយ"[12]។

៨. នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ សហមេធាវីបានដាក់ "សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ("សារណាបន្ថែម") ដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះ (១) សម្រេចទទួលយកសារណាបន្ថែម (២) ប្រកាសថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ត្រូវទុកជាមោឃៈ និង (៣) ផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ក្នុងសំណុំរឿង ០០៣[13]។

៩. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានចេញ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង" ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២") ដោយបដិសេធអង្គសេចក្តីនៃបណ្តឹងសាទុក្ខភ្លាមៗ ដែលបានដាក់នៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២០[14] និងបានបិទបញ្ចប់សំណុំរឿង ០០៤/២[15]។

១០. នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើ ដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះ (១) សម្រេចទទួលយកសំណើ[16] (២) ធានាថា បញ្ហាដែលបានលើកឡើងត្រូវបានដោះស្រាយតាមវិធីមួយដែលនាំឲ្យមានភាពប្រាកដប្រជា ភាពច្បាស់លាស់ និងការបញ្ចប់ជាស្ថាពរ

---

[12] សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង។

[13] សំណុំរឿង ០០៣ សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០, ឯកសារ D267/27 ("សារណាបន្ថែមរបស់ មាស មុត (D267/27)")។

[14] សំណុំរឿង ០០៤/២ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០, ឯកសារ E004/2/1 ("បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២ (E004/2/1)")។

[15] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០, ឯកសារ E004/2/1/1/2 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ ក្នុងសំណុំរឿង ០០៤/២ (E004/2/1/1/2)")។

[16] សំណើ (D266/22) កថាខណ្ឌ ៩-១០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

តាមផ្លូវច្បាប់[17] និង (៣) បង្វិលសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដោយធ្វើការណែនាំឱ្យចេញដីកាដំណោះស្រាយតែមួយ ឬបញ្ជូនករណីខ្វែងយោបល់ជាផ្លូវការទៅអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយជាស្ថាពរ[18]។

១១. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ សហមេធាវីបានដាក់ "ចម្លើយតបរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត" ("ចម្លើយតប")[19]។ ពួកគេបានលើកឡើងនៅក្នុងចម្លើយតបថា អង្គបុរេជំនុំជម្រះគួរ (១) ច្រានចោលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយហេតុថាមិនអាចទទួលយកបាន (២) បដិសេធចោលសំណើសុំដំណោះស្រាយ (៣) ទុកជាមោឃៈនូវដីកាដំណោះស្រាយខុសច្បាប់ទាំងនោះនៅក្នុងសំណុំរឿង ០០៣ និង (៤) បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ[20]។

## II. សារណា

១២. នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖ (១) សម្រេចទទួលយកសំណើ[21] (២) ធានាថា បញ្ហាដែលបានលើកឡើងត្រូវបានដោះស្រាយតាមវិធីមួយដែលនាំឱ្យមានភាពប្រាកដប្រជា ភាពច្បាស់លាស់ និងការបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់[22] និង (៣) បង្វិលសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដោយធ្វើការណែនាំឱ្យចេញដីកា

---

[17] សំណើ (D266/22) កថាខណ្ឌ ១១-១២។

[18] សំណើ (D266/22) កថាខណ្ឌ ១៣-១៧។

[19] សំណុំរឿង ០០៣ ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ឯកសារ D266/23 ("ចម្លើយតប (D266/23")។

[20] ចម្លើយតប (D266/23) ទំព័រ ១៩។

[21] សំណើ (D266/22) កថាខណ្ឌ ៩-១០។

[22] សំណើ (D266/22) កថាខណ្ឌ ១១-១២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ដំណោះស្រាយតែមួយ ឬបញ្ជូនករណីខ្វែងយោបល់ជាផ្លូវការទៅអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយជាស្ថាពរ[23]។

១៣. ពាក់ព័ន្ធនឹងភាពអាចទទួលយកបាន សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សំណើរបស់ខ្លួនអាចទទួលយកបាន ដោយសារ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ ដែលសម្រេចថា ពុំមានដីកាដំណោះស្រាយណាមួយក្នុងសំណុំរឿង ០០៤/២ មានអានុភាពខាងផ្លូវច្បាប់នោះ បង្កើតយុត្តិសាស្ត្រថ្មី ដែលពាក់ព័ន្ធផ្ទាល់ និងមានសិទ្ធិអំណាច ចេញពីតុលាការចុងក្រោយរបស់ អ.វ.ត.ក ដែលមិនអាចប្រមើលមើលដឹងជាមុន និងដែលអនុញ្ញាតឱ្យមានអំណះអំណាងបន្ថែមពីភាគីនានាក្នុងសំណុំរឿង ០០៣[24]។ ដោយសារសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលគឺជាឯកសារយោងសំអាងផ្លូវច្បាប់ដ៏គួរឱ្យជឿជាក់ សេចក្តីសម្រេចដែលបានលើកឡើងនេះ ប៉ះពាល់ដោយផ្ទាល់លើការពិភាក្សារបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿងនេះ ហេតុនេះត្រូវយកសំណើនេះមកពិចារណា[25]។

១៤. ជាងនេះទៀត សំណើនេះក៏អាចទទួលយកបានផងដែរ ដែលស្របតាមអាណត្តិការងាររបស់ អ.វ.ត.ក ក្នុងការដំណើរការកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ស្របទៅនឹងគោលការណ៍នៃភាពយុត្តិធម៌ នៃភាពត្រឹមត្រូវ[26] និង ដើម្បីចៀសវាងនូវភាពមិនប្រាកដប្រជាខាងផ្លូវតុលាការមួយទៀត ដែលធ្វើ

---

[23] សំណើ (D266/22) កថាខណ្ឌ ១៣-១៧។

[24] សំណើ (D266/22) កថាខណ្ឌ ៩-១០។

[25] សំណើ (D266/22) កថាខណ្ឌ ៩។

[26] សំណើ (D266/22) កថាខណ្ឌ *១០ យោងលើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១, នស/រកម/១០០៤/០០៦, ដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤, មាត្រា ៣៣។ *វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (វិសោធនកម្មលើកទី ៩) ដែលបានកែប្រែកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង"), វិធាន ២១(១)។

ឲ្យអន្តរាយដល់ការគ្រប់គ្រងវិស័យយុត្តិធម៌ដ៏ត្រឹមត្រូវ និងកាតព្វកិច្ចជាមូលដ្ឋានរបស់ចៅក្រម ក្នុងការដោះស្រាយបញ្ហានានានៅចំពោះមុខខ្លួន[27]។

១៥. ផ្អែកលើអង្គសេចក្តី ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា នាពេលបច្ចុប្បន្នពុំមានដីកាដំណោះស្រាយមានសុពលភាព ដែលធ្វើឲ្យសំណុំរឿងនេះបន្សល់ទុកនូវភាពអយុត្តិធម៌ និងមិនអាចទទួលយកបាន ដែលមិនទទួលបាននូវការបញ្ចប់តាមផ្លូវតុលាការ[28]។ ចំណុចនេះកើតមានដោយសារអង្គជំនុំជម្រះបានសម្រេចថា ការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់ ហើយបន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលសម្រេចថាដីកាទាំងនេះពុំមានអានុភាពតាមផ្លូវច្បាប់ លុះត្រាតែអង្គបុរេជំនុំជម្រះជ្រើសរើសបដិសេធសេចក្តីសម្រេចរបស់ខ្លួនវិញ[29]។ សហព្រះរាជអាជ្ញាអន្តរជាតិគូសបញ្ជាក់អំពីសិទ្ធិរបស់ភាគីនានា ជនរងគ្រោះ និងសាធារណជនកម្ពុជា ក្នុងការទទួលបានដំណោះស្រាយតាមផ្លូវតុលាការដែលច្បាស់លាស់ ជាក់លាក់ និងជាស្ថាពរ[30]។

១៦. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា វិធានសមស្របបំផុតគឺបង្វិលសំណុំរឿងនេះទៅសហចៅក្រមស៊ើបអង្កេតទាំងពីររូប ដោយមានក្របខណ្ឌពេលវេលាកំណត់ខ្លី និងណែនាំឲ្យពួកគេចេញដីកាដំណោះស្រាយតែមួយ ឬបញ្ជូនករណីខ្វែងយោបល់គ្នាជាផ្លូវការមកអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយ[31] ដើម្បីចៀសវាង "ការជាប់គាំងផ្នែកនីតិវិធីដែលអាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី"[32]។

១៧. ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនអាចចេញដីកាដំណោះស្រាយតែមួយបាន ហើយបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនមកអង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិលើកជាទឡ្ហីករណ៍ថា តាមរយៈក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក បញ្ហានេះត្រូវដោះស្រាយដោយគោលជំហរដើម

---

[27] សំណើ (D266/22) កថាខណ្ឌ ១០ *ដែលយោងទៅលើ*សេចក្តីពិចារណាលើសំណុំរឿង ០០៤/២ ( D359/24 និង D360/33) កថាខណ្ឌ ១២២។

[28] សំណើ (D266/22) កថាខណ្ឌ ១១។

[29] សំណើ (D266/22) កថាខណ្ឌ ១១។

[30] សំណើ (D266/22) កថាខណ្ឌ ១២។

[31] សំណើ (D266/22) កថាខណ្ឌ ១៣។

[32] សំណើ (D266/22) កថាខណ្ឌ ១៤។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ដែលមានន័យថា បញ្ជូនសំណុំរឿង (រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីជំនុំជម្រះ[33]។ ប្រការនេះនឹងនាំឲ្យមានការបញ្ចប់នូវបញ្ហានេះ ស្របទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២[34]។

១៨. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ពុំមានកាលៈទេសៈពិសេសដែលតម្រូវឲ្យអង្គបុរេជំនុំជម្រះចេញដីកាដំណោះស្រាយដោយខ្លួនឯងទេ[35]។ ទោះជាយ៉ាងណាក្ដី ប្រសិនបើអង្គជំនុំជម្រះជ្រើសរើសវិធីសាស្ត្រនេះ សហព្រះរាជអាជ្ញាអន្តរជាតិលើកជាទឡ្ហីករណ៍ថា គេត្រូវអនុវត្តតាមតក្កវិជ្ជាដូចគ្នា ហើយសំណុំរឿង (រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[36]។ ទោះបីជ្រើសរើសវិធីសាស្ត្រណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចផ្លូវច្បាប់ ក្នុងការប្រកាសសេចក្ដីសម្រេចផ្លូវច្បាប់ទៅលើបញ្ហាក្នុងវិវាទនេះដែរ[37]។

១៩. ទីបួន សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ចៅក្រមដែលដោះស្រាយស្ថានភាពនេះគួរអនុវត្តតាមយុត្តិសាស្ត្រដ៏គួរឲ្យជឿជាក់បានរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចថា យុត្តាធិការបុគ្គលត្រូវបានសម្រេចតែទៅលើថា តើជនសង្ស័យ/ជនត្រូវចោទ ជាកម្មាភិបាលខ្មែរក្រហមឬយ៉ាងណា[38]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងជាទឡ្ហីករណ៍ថា យុត្តាធិការបុគ្គលមិនមែនជាបញ្ហាពាក់ព័ន្ធនឹង មាស មុត ទេ[39]។ គាត់ថ្លែងថា ថាតើជនត្រូវចោទស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណា គឺជា "[គោលការណ៍ណែនាំចំពោះសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត] ស្ថិតក្នុងការអនុវត្តឆន្ទានុសិទ្ធិដោយឯករាជ្យរបស់ពួកគាត់ក្នុងកិច្ចស៊ើប

---

[33] សំណើ (D266/22) កថាខណ្ឌ ១៥។

[34] សំណើ (D266/22) កថាខណ្ឌ ១៥ *ដែលយោងទៅ*សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខផ្លាមៗ (E004/2/1/1/2) កថាខណ្ឌ ៦១។

[35] សំណើ (D266/22) កថាខណ្ឌ ១៣។

[36] សំណើ (D266/22) កថាខណ្ឌ ១៥-១៦។

[37] សំណើ (D266/22) កថាខណ្ឌ ១៦។

[38] សំណើ (D266/22) កថាខណ្ឌ ១៧ *ដែលយោងទៅលើ*សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក, សាលដីកា, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ("សាលដីកាលើសំណុំរឿង ០០១ (F28)") កថាខណ្ឌ ៧៩។

[39] សំណើ (D266/22) កថាខណ្ឌ ១៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.C.T.C.

សួរ"[40] ដោយសន្និដ្ឋានថា ការបំពានឆន្ទានុសិទ្ធិត្រូវតែយកមកអនុវត្តដើម្បីដោះស្រាយបញ្ហា មិនមែនការវិភាគទៅលើយុត្តាធិការនោះទេ[41]។

២០. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីលើកឡើងថា អង្គបុរេជំនុំជម្រះគួរ (១) ច្រានចោលសំណុំរឿងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយហេតុថាមិនអាចទទួលយកបាន (២) បដិសេធចោលសំណើសុំដំណោះស្រាយ (៣) ទុកជាមោឃៈនូវដីកាដំណោះស្រាយខុសច្បាប់ទាំងនោះនៅក្នុងសំណុំរឿង ០០៣ និង (៤) បង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតបោះត្រា និង ដាក់សំណុំរឿង ០០៣ ចូលទៅក្នុងបណ្ណសារ[42] ដោយសារសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចទទួលយកបាន[43] ដំណោះស្រាយដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនឹងមិនធានាដល់ភាពប្រាកដប្រជា ឬការបញ្ចប់ជាស្ថាពរឱ្យបានទាន់វេលាទេ[44] ហើយសហព្រះរាជអាជ្ញាបកស្រាយខុសអំពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការទៅលើយុត្តាធិការបុគ្គល[45]។

២១. ទីមួយ សហមេធាវីលើកឡើងថា សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចទទួលយកបាន[46] ដោយសារ (១) សំណើមិនបានដាក់ទាន់ពេលវេលា[47] និង (២) សំណើពុំមានមូលដ្ឋានត្រឹមត្រូវ[48]។

២២. ទាក់ទិននឹងទឡ្ហីករណ៍ដែលថា សំណើមិនបានដាក់ទាន់ពេលវេលា សហមេធាវីលើកឡើងថា (១) ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការ

---

[40] សំណើ (D266/22) កថាខណ្ឌ ១៧ *ដែលដកស្រង់*សាលដីកាលើសំណុំរឿង ០០១ (F28) កថាខណ្ឌ ៦២-៦៤, ៧៥, ៧៩។

[41] សំណើ (D266/22) កថាខណ្ឌ ១៧។

[42] ចម្លើយតប (D266/23) ទំព័រ ១៩។

[43] ចម្លើយតប (D266/23) កថាខណ្ឌ ២-១១។

[44] ចម្លើយតប (D266/23) កថាខណ្ឌ ១២-២៧។

[45] ចម្លើយតប (D266/23) កថាខណ្ឌ ២៨-៣០។

[46] ចម្លើយតប (D266/23) កថាខណ្ឌ ១។

[47] ចម្លើយតប (D266/23) កថាខណ្ឌ ២-៧។

[48] ចម្លើយតប (D266/23) កថាខណ្ឌ ៨-១១។

កំពូលក្នុងសំណុំរឿង ០០៤/២ មិនមែនមិនអាចប្រមើលដឹងជាមុន និងមិនអាចស្រមៃបាននោះទេ[49] (២) សហព្រះរាជអាជ្ញាអន្តរជាតិមានឱកាសយ៉ាងច្រើនក្នុងការពោលប្រាស្រ័យនូវបញ្ហានានាដែលពាក់ព័ន្ធនឹងដំណោះស្រាយនៃសំណុំរឿង ០០៣[50] (៣) សហព្រះរាជអាជ្ញាអន្តរជាតិលើកជាទឡ្ហីករណ៍នៅឯសវនាការក្នុងសំណុំរឿង ០០៣ ថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាត្រូវបានអនុញ្ញាតនៅក្រោមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ហើយថា សំណុំរឿងនេះបន្តដំណើរការទៅជំនុំជម្រះអនុលោមតាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ដោយសារពុំមានសំឡេងភាគច្រើនលើសលប់ពីអង្គបុរេជំនុំជម្រះ[51] (៤) នៅពេលមេធាវីការពារក្តីស្នើសុំការបញ្ជាក់បំភ្លឺពីអង្គបុរេជំនុំជម្រះ ក្រោយពេលចេញសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹងមូលដ្ឋានគតិយុត្តិដែលចៅក្រមនៃអង្គបុរេជំនុំជម្រះអាចពិចារណាដាច់ពីគ្នា ទៅលើអង្គសេចក្តីនៃដីកាដំណោះស្រាយខុសច្បាប់ សហព្រះរាជអាជ្ញាអន្តរជាតិនៅតែរក្សាជំហរថា អង្គជំនុំជម្រះសាលាដំបូងទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយស្វ័យប្រវត្តិ អនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង[52] (៥) សហព្រះរាជអាជ្ញាអន្តរជាតិបែរជាលើកឡើងថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាដោយខុសច្បាប់ ពុំបានធ្វើឲ្យដីកាទាំងនេះត្រូវចាត់ទុកជាមោឃៈ និង ឥតបានការទេ ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកបណ្តឹងនេះ នៅពេលមេធាវីការពារក្តីស្នើសុំដាក់សារណាបន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០៤/២ និងលទ្ធភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនអាចជំទាស់តវ៉ា នៅតាមលងបន្លាច មាស មុត ជារៀងរហូត[53] និង (៤) សហព្រះរាជអាជ្ញាអន្តរជាតិផ្លាស់ប្តូរជំហររបស់ខ្លួន ស្តីពីដំណោះស្រាយដែលអង្គបុរេជំនុំជម្រះមាននៅក្នុងសំណុំរឿងនេះ និងនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយពីរដំណាលគ្នា អស់រយៈពេលជាង ២៦០ថ្ងៃ ក្រោយពេលចេញសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ និងក្រោយពេលចេញសេចក្តី

[49] ចម្លើយតប (D266/23) កថាខណ្ឌ ២។

[50] ចម្លើយតប (D266/23) កថាខណ្ឌ ៣។

[51] ចម្លើយតប (D266/23) កថាខណ្ឌ ៤។

[52] ចម្លើយតប (D266/23) កថាខណ្ឌ ៥។

[53] ចម្លើយតប (D266/23) កថាខណ្ឌ ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. 11

សម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ ដែលមិនបានគាំទ្រដល់សារណាបន្ថែមឡើយ[54]។

២៣. ទាក់ទិននឹងទឡ្ហីករណ៍ដែលថា សំណើពុំមានមូលដ្ឋានត្រឹមត្រូវ សហមេធាវីលើកឡើងថា (១) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា ចាំបាច់ត្រូវមានសារណាបន្ថែមពីភាគីនានា[55] (២) អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចដោយច្បាស់ថា ការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាគឺខុសច្បាប់ បានធ្វើឲ្យដីកាទាំងនេះទុកជាមោឃៈ អសារបង់ និងគ្មានអានុភាពផ្លូវច្បាប់ "គោលជំហរដើម" មិនអាចអនុវត្តបានទេ ហើយអង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា សំណុំរឿងនេះគប្បីត្រូវបញ្ចប់[56] (៣) បើតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ លែងមានភាពមិនច្បាស់លាស់អ្វីទៀតហើយ ហើយការទទួលយកសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សារណាបន្ថែមគឺជាការពន្យារពេលក្នុងការសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០៣[57] និង (៤) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា សំណើរបស់ខ្លួនអាចទទួលយកបាន ចំណែកឯសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ ពុំបានលើកឡើងនូវបញ្ហាថ្មីៗទេ ហើយអង្គបុរេជំនុំជម្រះបានដឹងយ៉ាងទូលំទូលាយអំពីផលវិបាកផ្លូវច្បាប់ នៃការចេញដីកាដំណោះស្រាយផ្ទុយគ្នាដោយខុសច្បាប់ និងដំណោះស្រាយនានាដែលមាន មុនពេលចេញសេចក្តីសម្រេចនោះ[58]។

២៤. ទីពីរ សហមេធាវីអះអាងថា ដំណោះស្រាយដែលបានស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិនឹងមិនធានាដល់ភាពប្រាកដប្រជា ឬការបញ្ចប់ជាស្ថាពរឲ្យបានទាន់ពេលវេលាទេ ដោយសារ (១) ការចេញដីកាដំណោះស្រាយដែលកែតម្រូវឲ្យទាន់ពេលវេលាគឺមិនអាចធ្វើបាន[59] (២) ការបង្វិលសំ

[54] ចម្លើយតប (D266/23) កថាខណ្ឌ ៧។

[55] ចម្លើយតប (D266/23) កថាខណ្ឌ ៨។

[56] ចម្លើយតប (D266/23) កថាខណ្ឌ ៩។

[57] ចម្លើយតប (D266/23) កថាខណ្ឌ ១០។

[58] ចម្លើយតប (D266/23) កថាខណ្ឌ ១១។

[59] ចម្លើយតប (D266/23) កថាខណ្ឌ ១២-១៥។

ណុំរឿង ០០៣ ទៅសហចៅក្រមស៊ើបអង្កេតវិញមិនអាចធ្វើទៅបាន[60] (៣) អង្គបុរេជំនុំជម្រះមិនអាចបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនករណីខ្វែងយោបល់គ្នារបស់ខ្លួនទៅអង្គជំនុំជម្រះដើម្បីដោះស្រាយបានទេ[61] និង (៤) ដោយពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនោះ "គោលជំហរដើម" មិនអាចយកមកអនុវត្តបានទេ[62]។

២៥. ពាក់ព័ន្ធនឹងទឡ្ហីករណ៍ដែលថា ការចេញដីកាដំណោះស្រាយដែលកែតម្រូវឲ្យទាន់ពេលវេលាគឺមិនអាចធ្វើបាន សហមេធាវីកលើកឡើងថា (១) ការយល់ឃើញថា ការចេះញដីកាដំណោះស្រាយកែកែប្រែអាចធ្វើបានយ៉ាងឆាប់រហ័ស មិនអាចក្លាយជាការពិតបាន និងមិនអាចទៅរួចទេ ដោយសារចៅក្រមនៃអង្គបុរេជំនុំជម្រះមានការយល់ឃើញខុសគ្នាស្រឡះទៅលើការស៊ើបអង្កេត និងការសម្រេចសេចក្តីក្នុងសំណុំរឿង ០០៣[63] និង (២) ទោះបីអង្គបុរេជំនុំជម្រះស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ក្តី តែអង្គជំនុំជម្រះត្រូវការពេលវេលា និងធនធានជាច្រើនដើម្បីពិនិត្យឡើងវិញលើភស្តុតាងនៅក្នុងសំណុំរឿង ការពិភាក្សាសម្រេច និង ការតាក់តែងដីកាដំណោះស្រាយដែលកែប្រែដែលនឹងពន្យារពេលដល់ការសម្រេចសេចក្តីក្នុងសំណុំរឿង ០០៣[64]។

២៦. ពាក់ព័ន្ធនឹងទឡ្ហីករណ៍ថា ការបង្វិលសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេតវិញមិនអាចធ្វើទៅបាន សហមេធាវីលើកឡើងថា (១) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថាដំណោះស្រាយសមស្របបំផុត គឺការបង្វិលសំណុំរឿងទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ[65] ដោយសារការបង្វិលសំណុំរឿង ០០៣ ដើម្បីចេញដីកាដំណោះស្រាយតែមួយ "ដោយភ្ជាប់ក្របខណ្ឌពេលវេលាកំណត់ខ្លី" មិនអាចធ្វើទៅបានទេ ដោយសារប្រវត្តិនីតិវិធីពិសេសនៃសំណុំរឿង

---

[60] ចម្លើយតប (D266/23) កថាខណ្ឌ ១៦-២១។

[61] ចម្លើយតប (D266/23) កថាខណ្ឌ ២២-២៣។

[62] ចម្លើយតប (D266/23) កថាខណ្ឌ ២៤-២៧។

[63] ចម្លើយតប (D266/23) កថាខណ្ឌ ១៣។

[64] ចម្លើយតប (D266/23) កថាខណ្ឌ ១៤។

[65] ចម្លើយតប (D266/23) កថាខណ្ឌ ១៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

នេះ[66] (២) បុគ្គលិកថ្មីៗរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael BOHLANDER ចាំបាច់ត្រូវទទួលនូវបណ្តុះបណ្តាល និងពេលវេលា ដើម្បីស្វែងយល់ពីសំណុំរឿង ០០៣ ដែលបណ្តាលឱ្យមានការពន្យារពេល[67] (៣) អង្គបុរេជំនុំជម្រះក៏នឹងពិចារណាដល់ការបង្គាប់ណែនាំឱ្យសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ធ្វើការពិនិត្យមើលឡើងវិញទៅលើសំណុំរឿងទាំងមូល ក្នុងរយៈពេលខ្លី រួមទាំងភស្តុតាងដែលចំនួនរាប់ពាន់ដែលប្រមូលបាន ក្រោយពេលរូបគាត់ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ BLUNK បានបិទការស៊ើបអង្កេតរបស់ខ្លួននៅឆ្នាំ២០១១[68] (៤) លុះត្រាតែសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ត្រូវបានបង្គាប់ឱ្យពិនិត្យមើលវិញទៅលើសំណុំរឿងទាំងមូល នោះវានឹងមិនអាចទៅរួចទេដែលសហចៅក្រមស៊ើបអង្កេតឈានដល់ការស្រុះស្រួលគ្នា ហើយការកែប្រែឱ្យតែល្អមើលដែលធ្វើទៅលើដីកាដំណោះស្រាយតែមួយ នឹងមិនអាចដោះស្រាយបញ្ហាតុលាការរបស់ពួកគាត់ដែលធ្លាប់មានពីមុនមកទេ[69] និង (៤) ទោះបីសហចៅក្រមស៊ើបអង្កេតព្រមព្រៀងគ្នាលើលទ្ធផលរួមណាមួយក្តី ភាគីចៀសមិនរួចនឹងប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយដែលកែប្រែឡើយ ជាហេតុនាំឱ្យមានការពន្យារពេលបន្ថែមទៀត រហូតដល់អង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនេះ ហើយប្រសិនបើសំណុំរឿងនេះត្រូវបញ្ជូនទៅជំនុំជម្រះ ក៏ការជំនុំជម្រះនឹងមិនអាចចាប់ផ្តើមនៅមុនឆ្នាំ២០២៣ ឡើយ[70]។

២៧. ពាក់ព័ន្ធនឹងទឡ្ហីករណ៍ដែលថា អង្គបុរេជំនុំជម្រះមិនអាចបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនករណីខ្វែងយោបល់គ្នាមកអង្គជំនុំជម្រះដើម្បីដោះស្រាយ សហមេធាវីអះអាងថា (១) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនមកអង្គបុរេជំនុំជម្រះ ដោយពុំមានដីកាដំណោះស្រាយតែមួយ ដោយសារសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិក្នុងការចុះបញ្ជីករណីខ្វែងយោបល់របស់ខ្លួននៅក្នុងការិយាល័យ

---

[66] ចម្លើយតប (D266/23) កថាខណ្ឌ ១៧ និងលេខយោងជើងទំព័រ ៥០ *ដែលយោងទៅលើ*សំណើសុំការបញ្ជាក់បំភ្លឺ (D266/19 និង D267/24), កថាខណ្ឌ ៤៥-៤៦។ សារណាបន្ថែមរបស់ មាស មុត (D267/27) កថាខណ្ឌ ៣៣-៣៩។

[67] ចម្លើយតប (D266/23) កថាខណ្ឌ ១៨។

[68] ចម្លើយតប (D266/23) កថាខណ្ឌ ១៩។

[69] ចម្លើយតប (D266/23) កថាខណ្ឌ ២០។

[70] ចម្លើយតប (D266/23) កថាខណ្ឌ ២១។

01658518



របស់ខ្លួន ឬបញ្ជូនទៅអង្គបុរេជំនុំជម្រះ អនុលោមតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[71] និង (២) ប្រសិនបើភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងអ្នកតាក់តែងវិធានផ្ទៃក្នុងមានបំណងកំណត់យន្តការដោះស្រាយវិវាទជាលក្ខខណ្ឌតម្រូវចាំបាច់ នោះអ្នកទាំងនោះគួរតែបានព្រមព្រៀងគ្នាឲ្យមានយន្តការនេះយ៉ាងច្បាស់លាស់ទៅហើយ[72]។

២៨. ទាក់ទិននឹងការអះអាងរបស់ខ្លួនដែលថា ដោយពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព នោះ "គោលជំហរដើម" មិនអាចយកមកអនុវត្តបាន សហមេធាវីលើកឡើងថា (១) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា នៅពេលសហចៅក្រមស៊ើបអង្កេតមិនអាចចេញដីកាដំណោះស្រាយតែមួយបាន និង មិនអាចបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនទៅអង្គបុរេជំនុំជម្រះបាន អង្គបុរេជំនុំជម្រះគួរដោះស្រាយករណីនេះដោយអនុវត្ត "គោលជំហរដើម" និង បញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ក្នុងករណីពុំមានសំឡេងភាគច្រើនលើសលប់ផ្ទុយពីនេះ[73] (២) "គោលជំហរដើម" មិនអាចយកមកអនុវត្តបានទេ នៅពេលដែលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយផ្ទុយគ្នា ហើយការណ៍នេះត្រូវបានពន្យល់ជាច្រើនលើក និងត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល[74] (៣) អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា "គោលជំហរដើម" ត្រូវយកមកអនុវត្តនៅពេលណាពុំមានសំឡេងភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះ ដើម្បីគាំទ្រការលើកលែងចោទប្រកាន់ គឺ"មិនអើពើចំពោះ [...] ការយល់ឃើញជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះដែលថា ដីកាដំណោះស្រាយ [ផ្ទុយគ្នា] គឺជាលទ្ធផលនៃ*ចំណាត់ការខុសច្បាប់ និង ពុំត្រឹមត្រូវតាមច្បាប់*" ហើយអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចយ៉ាងជាក់លាក់ថា សំណុំរឿងមិនអាចបញ្ជូនទៅជំនុំជម្រះបានទេ ក្នុងករណីពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព[75] និង (៤) ប្រសិនបើសហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនករណីខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះនោះ ការណ៍នេះ

---

[71] ចម្លើយតប (D266/23) កថាខណ្ឌ ២២។

[72] ចម្លើយតប (D266/23) កថាខណ្ឌ ២៣។

[73] ចម្លើយតប (D266/23) កថាខណ្ឌ ២៤។

[74] ចម្លើយតប (D266/23) កថាខណ្ឌ ២៥។

[75] ចម្លើយតប (D266/23) កថាខណ្ឌ ២៦។



PRE-TRIAL CHAMBER E.C.C.C.

នឹងនាំទៅរកតែកិច្ចមួយដែលឆ្កាំផ្គង និងខ្វះខ្នាតពេលវេលា ដោយសារមិនមានដីកាដំណោះស្រាយមានសុពលភាព ករណីខ្វែងយោបល់គ្នានឹងក្លាយទៅជា*សំណើសុំ* ឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាសម្រេចលើកលែងចោទប្រកាន់ ហើយប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលប់បានទេ នោះ "ការស៊ើបអង្កេតត្រូវបន្តទៅមុខ"[76]។

២៩. ចុងក្រោយ សហមេធាវីលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយមិនត្រឹមត្រូវនូវយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលលើយុត្តាធិការបុគ្គល ដោយសារ (១) សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា យុត្តាធិការបុគ្គលមិនស្ថិតក្នុងបញ្ហានេះឡើយ[77] (២) អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ជនទាំងពីរប្រភេទនៃកម្មាភិបាលខ្មែរក្រហមដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ត្រូវតែ "[...] *ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត*" ហើយទោះបីអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការកំណត់ថាតើជនត្រូវចោទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬទេ គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតក្តី ក៏ការណ៍នេះនឹងមិនប៉ះពាល់ដល់លក្ខខណ្ឌតម្រូវថា សេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយផ្អែកលើ "គោលការណ៍ច្បាប់ដែលមានច្បាស់លាស់"[78] និង (៣) ការបកស្រាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីយុត្តាធិការបុគ្គលគឺផ្ទុយពីក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងយុត្តិសាស្ត្រ ព្រមទាំងសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួនផ្ទាល់ ដោយសារយុត្តាធិការបុគ្គលមិនដែលត្រូវបានកំណត់ដោយផ្អែកតែទៅលើមូលដ្ឋានថា ជនត្រូវចោទជាកម្មាភិបាលខ្មែរក្រហមនោះទេ[79]។

## III. ការពិភាក្សា

---

[76] ចម្លើយតប (D266/23) កថាខណ្ឌ ២៧។

[77] ចម្លើយតប (D266/23) កថាខណ្ឌ ២៨ និងលេខយោងជើងទំព័រ ៨៤ *ដែលយោងទៅលើសំណើ* (D266/22) កថាខណ្ឌ ១៧។

[78] ចម្លើយតប (D266/23) កថាខណ្ឌ ២៩។

[79] ចម្លើយតប (D266/23) កថាខណ្ឌ ៣០។

៣០. អង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នានៅក្នុងសំណុំរឿង ០០៣[80]។ នាពេលនេះ កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងនេះត្រូវបានបិទបញ្ចប់ហើយ ហើយអង្គបុរេជំនុំជម្រះពិនិត្យមើលទឡ្ហីករណ៍ពីភាគី និងពិភាក្សាសម្រេចលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង។

៣១. តាំងពីដំបូងមក អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការចេញសេចក្តីសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងកិច្ចដំណើរការនីតិវិធីផ្សេងគ្នា ពុំមានផលប៉ះពាល់ដោយផ្ទាល់ទៅលើសំណុំរឿងដែលកំពុងរង់ចាំការសម្រេចនេះទេ ជាពិសេស ពាក់ព័ន្ធនឹងតួនាទីរបស់អង្គបុរេជំនុំជម្រះជាយុត្តាធិការតែមួយនិងចុងក្រោយទៅលើបញ្ហានានាមុនការជំនុំជម្រះ[81]។

៣២. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា គោលការណ៍យុត្តិធម៌ និងភាពត្រឹមត្រូវត្រូវបានគោរពយ៉ាងតឹងរ៉ឹងនៅក្នុងសំណុំរឿងនេះ ដោយសារបណ្តឹងឧទ្ធរណ៍ត្រូវបានដឹងយ៉ាងទូលំទូលាយតាមរយៈសារណាជាលាយលក្ខណ៍អក្សរ និងការអះអាងដោយផ្ទាល់មាត់ពីភាគីនានា ក្នុងអំឡុងពេលសវនាការរយៈពេលបីថ្ងៃ[82]។

៣៣. ទាក់ទិននឹងការលើកឡើងបែបស្មានៗដែលថា សំណុំរឿងនេះនឹងនាំឲ្យមាន "ភាពមិនប្រាកដប្រជាខាងផ្លូវតុលាការមួយទៀត ដែលធ្វើឲ្យអន្តរាយដល់ដំណើរការដ៏ត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ និងកាតព្វកិច្ចជាមូលដ្ឋានរបស់ចៅក្រម ក្នុងការដោះស្រាយបញ្ហានានានៅចំពោះមុខខ្លួន"[83] អង្គបុរេ

---

[80] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3)។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត (D267/4)។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2)។

[81] *សូមមើល ឧទា.* វិធាន ៧៣, ៧៦(៤), ៧៧(១៣), ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ* សេចក្តីពិចារណាលើសំណុំរឿង ០០៤/២ (D359/24 និង D360/33) កថាខណ្ឌ ៤៩។

[82] សំណុំរឿង ០០៣ ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D266/12។

[83] សំណើ (D266/22) កថាខណ្ឌ ១០។



អង្គបុរេជំនុំជម្រះ * E.C.C.C * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ជំនុំជម្រះសូមរម្លឹកដល់គោលជំហរយ៉ាងខ្ជាប់ខ្ជួនរបស់ខ្លួនថា អង្គជំនុំជម្រះមិនធ្វើការសម្រេចដោយផ្អែកលើការឧបមាស្មានៗនោះឡើយ[84]។

៣៤. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមពិតទៅ សំណើនេះកំពុងស្នើសុំឱ្យមានការសម្រេចសេចក្តីស្តាពរពីអង្គជំនុំជម្រះ នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ ដែលនឹងត្រូវចេញក្នុងពេលវេលាមួយសមស្រប។ ពុំមានមូលហេតុណាមួយដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចឆាប់រហ័សពេក ទៅលើបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ដែលកំពុងដំណើរការនោះទេ។

៣៥. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើមិនអាចទទួលយកបានទេ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធ** សំណើ ដោយហេតុថាមិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២០**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

[84] *សូមមើល ឧទា.* សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ១១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៨។ សំណុំរឿង ០០២ (អបជ០១) សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ឯកសារ C11/53 កថាខណ្ឌ ៤៨។